ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩០៦/១៦-១០-១៣

សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២៧-៨-២០១៤ ដែលមានសមាសភាពដូចតទៅៈ

**សាលដីកា**
លេខ ៤៦ ក្រ.ឃ.ចុះ
ថ្ងៃទី ០៥-៩-២០១៤

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៩០៦ ចុះថ្ងៃទី ១៦-១០-២០១៣ រវាង ៖

-ជនជាប់ចោទឈ្មោះ

១-[redacted] **ហ៊ឹម** ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ-កើតនៅភូមិ-[redacted] មានទីលំនៅសព្វថ្ងៃផ្ទះ[redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០២នាក់ (ឃុំខ្លួន)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ឈឿន**, [redacted] **សេដ្ឋា**។ (ប្តឹងឧទ្ធរណ៍)

**ត្រូវជាប់ចោទពីបទ** ៖ ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១-៨-២០១១ តាមបញ្ញត្តិមាត្រា ៣៧៧,៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

២-[redacted] **វឌ្ឍា** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ[redacted] ទីលំនៅសព្វថ្ងៃផ្ទះ[redacted] ឪពុកឈ្មោះ[redacted] "ស" ម្តាយ



៣៤៦

ឈ្មោះ [redacted] "រ" ប្រពន្ធ ឈ្មោះ [redacted] មានកូនចំនួន០៣នាក់ ទោសពីមុនគ្មាន (ប្តឹង-ឧទ្ធរណ៍)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ស៊ីណាល់**។

២-[redacted] **ហៀង** ភេទស្រី អាយុ៣៨ឆ្នាំ (មិនប្តឹងឧទ្ធរណ៍)

**ត្រូវជាប់ចោទពីបទ** ៖ ឆបោក

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១-៨-២០១១ តាមបញ្ញត្តិមាត្រា ៣៧៧, ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ

១-[redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅ[redacted]។ មានមេធាវីតំណាងឈ្មោះ [redacted] ឥម។

២-[redacted] ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ[redacted]។ មានមេធាវីតំណាងឈ្មោះ [redacted] ឥម។

**រឿងហេតុមានដូចតទៅ**

តាមពាក្យបណ្តឹងចុះថ្ងៃទី ៣០-៥-២០១២ របស់ឈ្មោះ [redacted] សារឹម, [redacted] រដ្ឋា បានបញ្ជាក់ថា កាលពីថ្ងៃទី ០១-៨-២០១១ ឈ្មោះ [redacted] ហ៊ីម បានធ្វើលិខិតប្រគល់ប្រាក់មកឱ្យខ្លួនចំនួន ៥០០$ ដោយនិយាយថា ចង់ទិញដីពីខ្លួនចំនួន ៧ ៨០០ហិកតា នៅកំពង់ធំ។ នៅពេលខ្លួនចុះទៅរៀបចំទីតាំងដីដែលបានសន្យាគ្នា គឺខ្លួនបានរៀបចំទីតាំងដីនៅខេត្តកំពង់ធំឱ្យទៅឈ្មោះ [redacted] ហ៊ីម បានចំនួន ២ ០០០ហិកតា មានការដឹងឮពីអាជ្ញាធរត្រឹមត្រូវ។ ពេលនោះឈ្មោះ [redacted] ហ៊ីម បានចេញមូលប្បទានប័ត្រលេខ ០១០៩៨៦ ចុះថ្ងៃទី ០៨-៨-២០១១ ដែលមានទឹកប្រាក់ចំនួន៤ ៦៨០ ០០០$ មកឱ្យខ្លួន ពេលខ្លួនទៅបើកប្រាក់នៅធនាគារ ភ្នាក់ងារធនាគារប្រាប់ថា មូលប្បទានប័ត្រនេះពុំមានសាច់ប្រាក់ទេ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥៩ "ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក/-ឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០៛(បួនលាន)រៀល ពីបទៈ ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១-៨-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៧៧,៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

ខ/-ឈ្មោះ [redacted] ហៀង ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០១"មួយ"ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១-៨-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៧៧,៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីម [redacted] ហៀង , [redacted] រដ្ឋា រួមគ្នាសងសំណងអន្តរាយ និងជម្ងឺចិត្តជាប្រាក់ចំនួន ៣០ ០០០ ០០០៛ "សាមសិបលាន" រៀល ឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សារីម , [redacted] រដ្ឋា សំណើរលើសពីនេះបដិសេធចោល។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៥-៧-២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤-៨-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ីម កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៀង ឈ្មោះ [redacted] រដ្ឋា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] , [redacted]។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-១១-២០១៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចទី២ នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១២-២០១៣ របស់លោក [redacted] **ស៊ីណាល់** ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **រដ្ឋា** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩-៨-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **ហ៊ីម** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ១០-០២-២០១៤។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២៥-៣-២០១៤។

## **<u>នាពេលសវនាការសាលាឧទ្ធរណ៍</u>**

ចៅក្រមអានរបាយការណ៍រឿង

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted] រដ្ឋា

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted] សារីម , [redacted] រដ្ឋា

-ឈ្មោះ [redacted] ហ៊ីម បានឆ្លើយថា មូលប្បទានប័ត្រដែលខ្លួនចេញចំនួន ៤ ៦៨០ ០០០$ សំរាប់ទូទាត់ថ្លៃដីចំនួន ៧៨០០ហិកតា និងគាត់ដកបាននៅពេលមានដីគ្រប់ចំនួន ហើយនៅក្នុងកិច្ចសន្យាពេលណាគាត់កាត់ប្លង់នៅសុរិយោដីស្រុកហើយខ្លួនទូទាត់ឱ្យគាត់ចំនួន៥០% ។ ខ្លួនទិញដីចង់បានដីស្រែសំរាប់ធ្វើកសិកម្មដល់ពេលនាំខ្លួនទៅមើលដីដែលធ្វើប្លង់រួចហើយជាដីព្រៃព្រមទាំងមានការហាមឃាត់របស់រដ្ឋទៀត។ ខ្លួននៅតែចង់បានដី និងពេលណាមានដីពេលនោះមានប្រាក់ ហើយសែកនេះខ្លួនជាអ្នកចុះហត្ថលេខាទើបអាចបើកប្រាក់បាន រីឯសែកដែលយកទៅបើកប្រាក់មិនបាននេះដោយសារគាត់មិនបានបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យា។ ចំពោះឈ្មោះ [redacted] ហៀង គ្រាន់តែរៀបចំពិនិត្យអត្តសញ្ញាណប័ត្រ ផ្តិតមេដៃ រីឯឈ្មោះ [redacted] រដ្ឋា គាត់ស្គាល់ឈ្មោះ [redacted] ផល្លី គាត់ជូនខ្លួនទៅដើម្បីទំនាក់ទំនងទិញប៉ុណ្ណោះ មិនអាចទៅឃុបឃិតជាមួយខ្លួនមានសិទ្ធិអី។

ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា**

-បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីម, [redacted] រដ្ឋា ,យ៉ន ស៊ីណាល់ មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] រដ្ឋា និងបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥,៣៧៦,៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ទាក់ទិនរឿងនេះតំណាងមហាអយ្យការជូនក្រុមប្រឹក្សាពិចារណាទៅតាមច្បាប់ ប៉ុន្តែតាមចំណាររបស់ឯកឧត្តមអគ្គរងសុំឱ្យក្រុមប្រឹក្សាពិចារណាតាមការទិញលក់ដីនេះមិនទាន់មានការផ្ទេរសិទ្ធិឱ្យមានការចុះបញ្ជីត្រឹមត្រូវទេ បើយកប្រាក់ពីឈ្មោះ [redacted] ហ៊ីម ចែកអ្នកម្ចាស់ដីអស់ ហើយការកាត់ឈ្មោះត្រឹមត្រូវមិនបានអ្នកណាជាអ្នកទទួលខុសត្រូវ, ដីនៅជាដីមិនបាត់ទៅណាទេ សែកនៅតែជាសែក,សព្វថ្ងៃដីបានគេទិញរួចហើយ ប្រជាពលរដ្ឋបានមកអុកឡុកមានច្រើនណាស់។

-មេធាវី [redacted] គីម តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ទាក់ទងសំណុំរឿងនេះក្រោយពីបានស្តាប់ការសួរដេញដោល និងចម្លើយរបស់ជនជាប់ចោទ គឺមានសំដីឆ្លើយដោះសារតែពុំមានភស្តុតាង, ដីដែលកូនក្តីខ្លួនបានផ្ទេរទៅឱ្យឈ្មោះ [redacted] ហ៊ីម មានចំនួន ២០០០ហិកតាហើយ គឺមានស្នាមមេដៃរបស់ឈ្មោះ [redacted] ហ៊ីម និង [redacted] ហៀង ទាំងអស់នៅខេត្តកំពង់ធំ និងផ្ទេរទាំងអស់ សព្វថ្ងៃកំពុងជាប់បំណុលរបស់អ្នកស្រុក, កូនក្តីខ្លួនខាតលុយអស់ជិត ៣០ម៉ឺនដុល្លាអាមេរិក។ កូនក្តីខ្លួនបានផ្ទេរដីចំនួន ២០០០ហិកតា នៅថ្ងៃទី ២៨-៧-២០១១ គឺថ្ងៃតែមួយ ដោយឡែកសែកនេះទើបតែចេញនៅថ្ងៃទី ០៨-៨-២០១១ ហើយនៅសាលាដំបូងបានសួរ គាត់ថា សែកដែលចេញនេះអត់មានប្រាក់ទេ តែមកដល់ពេលនេះគាត់ថា ទាល់តែគាត់ស៊ីញ៉េទៀតទើបបើកបាននេះជាសំដីដោះសារទេ ហើយសំណងដែលសម្រេចឱ្យ ៣០លានរៀលមិនគ្រប់ថ្លៃទិញដីពីប្រជាពលរដ្ឋទេ គឺបានចំណាយអស់ចំនួន២០ម៉ឺនដុល្លាអាមេរិក កូនក្តីខ្លួនប្តឹងឧទ្ធរណ៍នេះប្តឹងទាមទារសំណងចំនួន ២០ ម៉ឺនដុល្លាអាមេរិក តាមពាក្យបណ្តឹងពីសាលាដំបូង។

-មេធាវី [redacted] សេដ្ឋា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានបញ្ជាក់ច្បាស់ហើយថា សែកមានលុយ បើមានដីគ្រប់ទៅបើកបានភ្លាម និងនៅក្នុងកិច្ចសន្យាបានបញ្ជាក់ថា ទាល់តែដីស្រែពុំមែនដីរដ្ឋទេ។ ខ្លួនសំណូមពរសុំលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួន។

-មេធាវី [redacted] លៀង ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់មេធាវីសហភាតាបានលើកឡើង និងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ, បើនិយាយពីកិច្ចសន្យាទាក់ទិនក្នុងការអនុវត្តសែកខាងធនាគារអត់មាន ១ តែក្នុងដៃឈ្មោះ [redacted] ផល្លី តែប៉ុណ្ណោះ ដើម្បីអនុវត្តសែកនេះបានទាល់តែមានកិច្ចសន្យា តែក្នុងសំណុំរឿងអត់មានកិច្ចសន្យា ហើយដីនេះទៀតសោតមិនបានគ្រប់ចំនួន ៧៨០០ហិកតា ដូច្នេះការទូទាត់លុយអត់ទាល់កើតមានឡើងដែរ និងដីសុទ្ធជាដីព្រៃរបស់រដ្ឋ។ ដូច្នេះភាគីឈ្មោះ [redacted] ហ៊ីម មិនមែនអ្នកបោកទេ គឺភាគីអ្នកលក់ដីជាអ្នកបោកដោយសារអត់មានដីពិតប្រាកដ។ ខ្លួនសំណូមពរ

ដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់យុត្តិធម៌ដល់កូនក្តីរបស់ខ្លួន។

-មេធាវី [redacted] ស៊ីណាល់ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសុំគាំទ្រចំណាររបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា និងសុំឱ្យក្រុមប្រឹក្សាពិចារណាពីលិខិតផ្ទេរសិទ្ធិដីមួយៗ សុទ្ធតែជាង ១០០ហិកតា ហើយតម្លៃដីអត់មានដាក់ទេ បើតាមច្បាប់ភូមិបាលអចលវត្ថុលក់គ្មានតម្លៃមិនអាចយកជាការបានទេ។ ពាក់ព័ន្ធជាមួយសែក គឺសរសេរហើយដីទំហំ ៧៨០០ហិកតា មកឱ្យគាត់បាន បើកលុយបាន តើមានដីមកពីណាបើលិខិតធ្វើដូចលេងសើចនេះ, លិខិតធ្វើសុទ្ធតែដីជាង ១០០ហិកតា តែមិនបានដាក់តម្លៃទេ ម្យ៉ាងទៀតកូនក្តីខ្លួនមិនបានពាក់ព័ន្ធក្នុងរឿងនេះទេ បើចោទគាត់សមគំនិតទាល់តែគាត់មានប្រយោជន៍ក្នុងរឿងហ្នឹង តែពុំមានសោះ ការចោទប្រកាន់សុទ្ធតែជាវិមតិសង្ស័យ និងសុំក្រុមប្រឹក្សាពិចារណាលើមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ, មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ខ្លួនសំណូមសុំឱ្យក្រុមប្រឹក្សាអនុញ្ញាតឱ្យកូនក្តីរួចផុតពីបទចោទប្រកាន់។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-១១-២០១៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈ្មោះ [redacted] និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩-៨-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៧៥,៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ចំពោះមូលប្បទានប័ត្រចុះថ្ងៃទី ០៨-៨-២០១១ របស់ធនាគារ Sacom Bank ដែលមានទឹកប្រាក់ចំនួន ៤ ៦៨០ ០០០$ គឺខ្លួនចេញឱ្យដើម្បីតម្កល់ធានាការរៀបដីតាមកិច្ចសន្យា ហើយសែកនេះមិនមែនអត់ប្រាក់ទេ តែមានផុតកំណត់ពេលដកប្រាក់បាន។ អ្នករកដីឱ្យខ្លួនមានឈ្មោះ [redacted] ផល្លី , [redacted] សារឹម , [redacted] រដ្ឋា នៅពេលចុះកិច្ចសន្យាខ្លួនបានកក់ប្រាក់ឱ្យចំនួន៥០០$ សំរាប់ថ្លៃដំណើរការ អ្នកលក់ថា មានដីចំនួន១ម៉ឺនហិកតា ខ្លួនថាដីព្រៃខ្លួនពុំយកទេ យកដីស្រែ គោលបំណងក្រុមហ៊ុនខ្លួនទិញចំនួន ៣ម៉ឺនហិកតា។ ចំពោះឈ្មោះ [redacted] រដ្ឋា និងប្រពន្ធខ្លួនឈ្មោះ [redacted] ហៀង មិនបានដឹងថា ខ្លួនចេញសែកទេ។ ខ្លួនពិតជាបានឱ្យប្រពន្ធផ្តិតមេដៃលើពាក្យសុំកាន់កាប់ប្រើប្រាស់ដីជាមួយខ្លួន ដើម្បីយកទៅរត់ការជាមួយស្រុកមែន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួន និងឈ្មោះ [redacted] ហ៊ីម ទើបស្គាល់គ្នានៅឆ្នាំ ២០១២ ហើយមិនដែលស្គាល់ឈ្មោះ [redacted] សារឹម , [redacted] រដ្ឋា នេះដែរ។ ខ្លួមិនដែលជាបុគ្គលិករបស់ក្រុមហ៊ុន ហើយក៏មិនដែលរកស៊ីជាមួយដើមបណ្តឹងដែរ ចំណែកឈ្មោះ [redacted] ហ៊ីម ចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ឱ្យទៅភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនពុំបានដឹងទេ។

៤-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឹម , [redacted] រដ្ឋា បានបញ្ជាក់ថា កាលពីថ្ងៃទី ០១-៨-២០១១ ឈ្មោះ [redacted] ហ៊ីម បានធ្វើលិខិតប្រគល់ប្រាក់មកឱ្យខ្លួនចំនួន ៥០០$

ដោយនិយាយថា ចង់ទិញដី ៧៨០០ហិកតា នៅខេត្តកំពង់ធំ ហើយពួកខ្លួនចុះទៅរៀបចំតាមការសន្យាគ្នា ដោយរៀបដីឱ្យបានចំនួន ២០០០ហិកតា ដោយមានឯកសារដឹងឮពីអាជ្ញាធរត្រឹមត្រូវ ពេលនោះឈ្មោះ [redacted] ហ៊ីម បានចេញមូលប្បទានប័ត្រលេខ ០១០៩៨៦ ចុះថ្ងៃទី ០៨-៨-២០១១ ដែលមានទឹកប្រាក់ចំនួន ៤ ៦៨០ ០០០$ មកឱ្យខ្លួន នៅពេលទៅបើកប្រាក់ ភ្នាក់ងារធនាគាថា មូលប្បទានប័ត្រនេះពុំមានសាច់ប្រាក់ឡើយ។ ពួកខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ហ៊ីម ឈ្មោះនេះសន្យាថា ដោះស្រាយឱ្យ ប៉ុន្តែពុំមែនជាការពិតឡើយ។

៥-រឿងក្តីនេះសាលាដំបូងបានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈច្បាស់លាស់ហើយ ហេតុដូច្នេះសភាព្រហ្មទណ្ឌឯកភាពតាមសំអាងហេតុនេះ ពុំចាំបាច់លើកយកសំអាងហេតុដដែលមកបញ្ជាក់ជាថ្មីទៀតឡើយ។

៦-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានបង្ហាញពីចេតនាទុច្ចរិតដើម្បីឱ្យជនរងគ្រោះឈ្មោះ [redacted] សារីម , [redacted] រដ្ឋា ,ឈ្មោះ [redacted] ផល្លី មានការជឿទុកចិត្តជួយរៀបចំទិញដីឱ្យនៅខេត្តកំពង់ធំ ដោយចេញមូលប្បទានប័ត្រលេខ ០១០៩៨៦ ចុះថ្ងៃទី ០៨-៨-២០១១ ដាក់ទឹកប្រាក់ចំនួន ៤ ៦៨០ ០០០$ តែគ្មានសាច់ប្រាក់ក្នុងគណនីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី រីឯឈ្មោះ [redacted] រដ្ឋា ក៏បានចូលរួមក្នុងសកម្មភាពចុះពិនិត្យដល់ទីតាំងដីនៅខេត្តកំពង់ធំជាមួយជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ហើយឈ្មោះ [redacted] ហៀង ក៏បានចូលរួមផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិកាន់កាប់ជាមួយឈ្មោះ [redacted] ហ៊ីម ជាប្តីផងដែរ។

៧-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ពិតជាពាក់ព័ន្ធក្នុងអំពើឆបោកជាមួយឈ្មោះ [redacted] ហ៊ីម មែន ប៉ុន្តែជននេះពុំបានទទួលផលប្រយោជន៍អ្វីពីឈ្មោះ [redacted] ហ៊ីម ឡើយ។ ហេតុដូច្នេះគប្បីក្រុមប្រឹក្សាពិចារណាអំពីកំរិតទណ្ឌកម្មតាមទំហំជាក់ស្តែង ដោយផ្អែកតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

៨-សាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៥-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ "ខ" ស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] រដ្ឋា គួរកែប្រែទៅជាទោសព្យួរវិញ ចំណុចផ្សេងពីនេះរក្សាទុកជាបាការដដែល។

**ហេតុដូច្នេះ**

**<u>ឧនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-១១-២០១៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted], ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩-៨-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

៣-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១២-២០១៣ របស់លោក [redacted] ស៊ីណាល់ ជាមេធាវី

ទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

៤-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៩"ន" ចុះថ្ងៃទី ១៤-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១"ខ" ស្តីពីទណ្ឌកម្មពន្ធនាគារលើឈ្មោះ [redacted] រដ្ឋា ត្រូវកែប្រែទៅជាទោសព្យួរវិញ។

-ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

៥-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៥-៩-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ,កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងចំពោះមុខមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

សាលដីកានេះបានចូលស្ថាពរ និងមានអានុភាពអនុវត្តលើឈ្មោះ នី ហ៊ីម ក្រៅពីនេះពុំមានអានុភាពអនុវត្តឡើយ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

| បានឃើញ | សាលាឧទ្ធរណ៍ថ្ងៃទី ០១ ខែ ១២ ឆ្នាំ ២០១៤ |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |